# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**សំណុំរឿងព្រហ្មទណ្ឌ**
**លេខៈ ៧៥៦**
ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០១៤
**សាលដីកា**
**លេខៈ ១១៨ ក្រV "ប.ស"**
ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០១៦

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី ១៦-៧-២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៦ ដែលមានសមាសភាពដូចខាងក្រោម៖

### ក្រុមប្រឹក្សាជំនុំជម្រះ

| | | |
|---|---|---|
| លោក | [redacted] | ជាប្រធានក្រុមប្រឹក្សា |
| លោក | [redacted] | ជាចៅក្រមប្រឹក្សា |
| លោកស្រី | [redacted] | ជាចៅក្រមប្រឹក្សា |

### តំណាងមហាអយ្យការ

| | | |
|---|---|---|
| លោក | [redacted] | ព្រះរាជអាជ្ញា |

### ក្រឡាបញ្ជីសវនាការ

| | |
|---|---|
| លោក | [redacted] |

ដើម្បីជំនុំជម្រះលើសំណុំរឿងសកាព្រហ្មទណ្ឌលេខៈ ៧៥៦ ចុះថ្ងៃទី ១៨-៨-២០១៤ របស់សាលាឧទ្ធរណ៍ដែលមាន៖

១-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ឆ្នាំ ជនជាតិនីហ្សេរីយ៉ា កើតនៅប្រទេសនីហ្សេរីយ៉ា ទីលំនៅមុនឃាត់ខ្លួន ផ្ទះជួលលេខៈ ១៧ B ផ្លូវ ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ឪពុកឈ្មោះ Samuel Uche Max "រ" ម្តាយឈ្មោះ Opolonia Nwoko "រ" (នៅលីវ) ។ ឃុំខ្លួនថ្ងៃទី ២៤-៩-២០១៣ (នៅពន្ធនាគារ ម១)

២-ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាតយ ៤១ឆ្នាំ ជនជាតិអូស្ត្រាលី រ (គ្រូបង្រៀន)កើតនៅប្រទេសអូស្ត្រាលី,ទីលំនៅមុនឃាត់ខ្លួនផ្ទះលេខៈ៣៣ផ្លូវ Buckingham ក្រុង Mt Hallen Queensland Austalia ឪពុកឈ្មោះ Barry Taylor "រ" ម្តាយឈ្មោះ MarleneWilson "រ" ប្តីឈ្មោះ Harley young (លែងលះ)។ឃុំខ្លួនថ្ងៃទី២៤-៩-២០១៣(ពន្ធនាគារ ម២)

៣-ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ១៩ឆ្នាំ ជនជាតិបារាំង មុខរបរធ្វើការនៅភោជនីដ្ឋាន LeDuo កើតនៅប្រទេសបារាំង ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះលេខ: ១៤ ផ្លូវ ៥៩ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ (នៅលីវ) ឪពុកឈ្មោះ Luigi Savarino "ស"ម្តាយឈ្មោះ Sylvie Rousselle "រ" ។ ឃុំខ្លួនថ្ងៃទី ២៤-៩-២០១៣ (នៅពន្ធនាគារ ម២)

៤-ជនជាប់ចោទឈ្មោះ [redacted] ហៅ NTO ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិនីហ្សេរីយ៉ា (NIGERIAN) កើតនៅ ONITSHA ប្រទេសនីហ្សេរីយ៉ា ទីលំនៅផ្ទះលេខ ១ A ផ្លូវលេខ ៤៥ BT ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាន់លិខិតឆ្លងដែនលេខ A04657209 ។ (គេចខ្លួន)

៥-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស ជាតិនីហ្សេរីយ៉ា កើតនៅក្រុងបេនីន ប្រទេសនីហ្សេរីយ៉ា (Benin City,Nigeria) កាន់លិខិតឆ្លងដែនលេខ: A01170452 ។ (គេចខ្លួន)

***ជាប់ចោទពីបទ:*** ដឹកជញ្ជូនដោយខុសច្បាប់ នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌ ដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

នៅថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ សមត្ថកិច្ចប្រទេសអូស្ត្រាលីបានធ្វើការចាប់ខ្លួនជនជាតិអូស្ត្រាលីឈ្មោះ [redacted] ភេទប្រុស អាយុ ៤២ឆ្នាំ និងឈ្មោះ I[redacted] Douglas ភេទប្រុស អាយុ ៤២ នៅប្រទេសអូស្ត្រាលី ដកហូតបានម្សៅហេរ៉ូអ៊ីនចំនួន ០៨Kg ។ ដែលជនល្មើសទាំងពីរបានទទួលពីជនត្រូវចោទឈ្មោះ N[redacted] ពីប្រទេសកម្ពុជា។បន្ទាប់មកសមត្ថកិច្ចប្រទេសអូស្ត្រាលីបានផ្តល់ពត៌មានមកនាយកដ្ឋានភារវកម្ម ក្រសួងមហាផ្ទៃ។នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៣ ឈ្មោះ [redacted] ហៅ NTO បានយកកាបូបស្ពាយមួយឱ្យជនត្រូវចោទឈ្មោះ N[redacted] នៅផ្ទះជួលលេខ ១៧ B ផ្លូវ ៥១០ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ដើម្បីប្រគល់ទៅឱ្យឈ្មោះ John ភេទប្រុស សញ្ជាតិអូស្ត្រាលី នៅ Brishane ប្រទេសអូស្ត្រាលី។នៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១១ និង ៣០នាទីព្រឹក ឈ្មោះ [redacted] បានប្រគល់កាបូបស្ពាយខាងលើទៅឱ្យឈ្មោះ [redacted] ប្រគល់បន្តឱ្យទៅជនត្រូវចោទឈ្មោះ [redacted] យកទៅប្រទេសអូស្ត្រាលី តាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។ ពេលដែលជនត្រូវចោទឈ្មោះ S[redacted] និង [redacted] យកកាបូបចូលដល់ក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក៏ត្រូវសមត្ថកិច្ចធ្វើការចាប់ខ្លួនអ្នកទាំងពីរព្រមទាំងឆែកឆេរកាបូបស្ពាយខាងលើ រកឃើញម្សៅហេរ៉ូអ៊ីនទម្ងន់ ២០០២,៤០g និងបន្តចាប់ខ្លួនឈ្មោះ [redacted]

លុះក្រោយពីចៅក្រមស៊ើបសួររួចមករកឃើញឈ្មោះ [redacted] ហៅ Ju[redacted] ភេទប្រុសជនជាតិនីហ្សេរីយ៉ាមានជាប់ពាក់ព័ន្ធក្នុងការទទួលគ្រឿងញៀននិងផ្ញើលុយឱ្យឈ្មោះ [redacted] ។

-រឿងនេះ សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ: ៥០ កប២ "ឥ" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៤ ដែលមានខ្លឹមសារថា៖

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិនីហ្សេរីយ៉ា Nigerian) ដាក់ពន្ធនាគារកំណត់ ២៧(ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០៛(ប៉ែតសិបលាន)រៀល ។

ខ-ឈ្មោះ [redacted] ភេទស្រី អាយុ ១៩ឆ្នាំ ជាតិបារាំង ដាក់ពន្ធនាគារកំណត់ ២៥(ម្ភៃប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០.០០០.០០៛ (ប៉ែតសិបលាន) រៀល ។

គ-ឈ្មោះ [redacted] ភេទស្រី អាយុ ៤១ឆ្នាំ ជាតិអូស្ត្រាលី ដាក់ពន្ធនាគារកំណត់ ២៣(ម្ភៃបី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០៛ (ប៉ែតសិបលាន) រៀល ។

ឃ-ឈ្មោះ [redacted] ហៅ NTO ភេទប្រុស អាយុ ៣៩ឆ្នាំ ជាតិនីហ្សេរីយ៉ា (NIGERIAN) ដាក់ពន្ធនាគារកំណត់ ២៧(ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០៛ (ប៉ែតសិបលាន) រៀល ។

ង-ឈ្មោះ [redacted] ភេទប្រុស ជាតិនីហ្សេរីយ៉ា (NIGERIAN) ដាក់ពន្ធនាគារកំណត់ ២៧(ម្ភៃប្រាំពីរ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៨០.០០០.០០៛ (ប៉ែតសិបលាន)រៀល ។

**ពីបទ:** ដឹកជញ្ជូនដោយខុសច្បាប់ នូវសារធាតុញៀន (ឆ្លងដែន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ដល់ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ហៅNTO និងឈ្មោះ [redacted] យកមកទទួលទោសតាមអំណាចសាលក្រមនេះតាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-វត្ថុតាងដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុតាងលេខ: ៥៩២ វ.ត ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៣ របស់ឃ្លាំងតម្កល់វត្ថុតាង របស់សាលាដំបូងរាជធានីភ្នំពេញ រួមមាន៖

ក-ហឹបដែកពណ៌សបិទជិត មានហត្ថលេខា គណៈកម្មការចូលរួមធ្វើការវេចខ្ចប់វត្ថុតាង និងស្នាមមេដៃជនសង្ស័យ ។ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១៧៦៩ អ.យ.ង ចុះថ្ងៃទី ២៣-៩-២០១៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញបញ្ជាក់ថា: ម្សៅហេរ៉ូអ៊ីន ទម្ងន់ ២០០២,៤០ក្រាម (ពីរពាន់ពីរក្បៀសសែសិប) ។

ខ-ក្រដាសពណ៌ក្រហមវេចខ្ចប់គ្រឿងញៀន និងកាបូបស្ពាយពណ៌ខ្មៅមួយត្រូវរឹបអូស។

គ-ទូរស័ព្ទដៃម៉ាក HTC ពណ៌ខ្មៅមួយគ្រឿង,ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌សមួយគ្រឿង

,ទូរស័ព្ទដៃម៉ាកសាំសុង Galaxy ពណ៌សមួយគ្រឿង និងទូរស័ព្ទដៃម៉ាកសាំងសុងស៊េរីចាស់ គ្មានថ្មចំនួនមួយគ្រឿង ។

ឃ-លិខិតឆ្លងដែនរបស់ឈ្មោះ N[redacted]លេខ A01722130 ។

ង-លិខិតឆ្លងដែនរបស់ឈ្មោះ N[redacted] លេខ A01047063 ។

ច-លិខិតឆ្លងដែនរបស់ឈ្មោះ T[redacted] លេខ N 4277246 ។

ឆ-ម៉ូតូម៉ាក Air Blande ពណ៌ខ្មៅពាក់ស្លាកលេខ ភ្នំពេញ ១AB-5138 មួយគ្រឿង។

ជ-រថយន្តម៉ាក CILECA ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2C-3335 ចំនួនមួយគ្រឿង។

ឈ-កុំព្យូទ័រយួរដៃម៉ាក ASUS ពណ៌ខ្មៅ មួយគ្រឿង។

ញ-កាបូបដៃចាស់ៗ០២ ។

ដ-លោហធាតុពណ៌សមួយចំនួន (ខ្សែក ក្រវិល....)។

ឋ-ឯកសារមួយចំនួន ។

ឌ-ឧបករណ៍អេឡិចត្រូនិចពណ៌ខ្មៅចំនួន ០២គ្រឿង ។

ឍ-កុំព្យូទ័រយួរដៃម៉ាក La Vie ពណ៌ស មួយគ្រឿង ។

ណ-ឧបករណ៍សម្រាប់សាកថ្មមួយចំនួន ។

ត-ឧបករណ៍ម៉ាក Hard Drive BY Hitachi ចំនួន ០១គ្រឿង ។

ថ-នាឡិកាដៃចំនួន ០៦គ្រឿង

ទ-ប្រាក់ដុល្លាអាមេរិកចំនួន ៤៦១ $ (បួនរយហុកសិបមួយដុល្លារអាមេរិក) ។

ធ-កាបូបស្ពាយសម្រាប់ដាក់កំព្យូទ័រយួរដៃ ០១។

ន-វ៉ាលីដាក់ខោអាវ ០២ ។

ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ។

-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ០៩ ខែមេសា ឆ្នាំ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ N[redacted] ជនជាប់ចោទឈ្មោះ [redacted] ជនជាប់ចោទឈ្មោះ [redacted],កំបាំងមុខជនជាប់ចោទឈ្មោះ C[redacted] ហៅ NTO និងជនជាប់ចោទឈ្មោះ A[redacted] Osaheni ។

-បើកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ៣៣៤ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៨ របស់ឈ្មោះ ~~Precious Chineme Nwoko~~ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៩០ កប២ "ឧ" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ១ នៃខ្លឹមសារទាំងមូល ។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ:៣៦១ ចុះថ្ងៃទី ២០-៦-២០១៨ របស់ឈ្មោះ

[redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៩០ កប២ "ធ" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល ។

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ: ៣៦៣ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២០១៤ របស់លោក ហុង គឹមសួន មេធាវីទទួលសិទ្ធិពីជនជាប់ចោទឈ្មោះ [redacted] ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ: ៩០ កប២ "ធ" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទី ១-២ នៃសេចក្តីសម្រេច ។

-បានឃើញ របាយការណ៍សង្ខេបអង្គហេតុចុះថ្ងៃទី២៧-០២-២០១៥ របស់សាលាឧទ្ធរណ៍ ។

-បានឃើញ របាយការណ៍សន្និដ្ឋានតំណាងមហាអយ្យការ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] (វត្តមាន)
-អ្នកបកប្រែភាសាឈ្មោះ [redacted] (វត្តមាន)
-មេធាវី: លោក [redacted] (វត្តមាន)
-ជនជាប់ចោទឈ្មោះ [redacted] (អវត្តមាន)
-អ្នកបកប្រែភាសាឈ្មោះ [redacted] (វត្តមាន)
-មេធាវី: លោក [redacted] (វត្តមាន)
-ជនជាប់ចោទឈ្មោះ [redacted] (វត្តមាន)
-អ្នកបកប្រែឈ្មោះ [redacted] (វត្តមាន)
-មេធាវី: លោក [redacted] (វត្តមាន)
-សាក្សី " ជាសមត្ថកិច្ច " លោក [redacted] (វត្តមាន)
-សាក្សី " ជាសមត្ថកិច្ច " លោក [redacted] (វត្តមាន)

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះអានសង្ខេបរបាយការណ៍រឿង**

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ ខ្ញុំប្តឹងឧទ្ធរណ៍ ព្រោះខ្ញុំពុំមានការពាក់ព័ន្ធជាមួយគ្រឿងញៀននោះទេ ខ្ញុំស្គាល់អ្នកទាំងពីរនេះគឺកញ្ញានេះជាមិត្តស្រីរបស់ខ្ញុំ ហើយម្នាក់ទៀតធ្លាប់រកស៊ីជាមួយគ្នា ខ្ញុំមកកម្ពុជានៅឆ្នាំ២០១៣ គាត់នៅជាមួយមិត្តភក្តិ នៅស្ទឹងមានជ័យ ជាជនជាតិនីសេរីយ៉ា។ខ្ញុំមិនដែលបានប្រគល់កាបូបឲ្យទៅកញ្ញា [redacted] ទេ ឈ្មោះ NTO ធ្លាប់បានរកស៊ីជាមួយខ្ញុំ ហើយគាត់បានយកកាបូបមកឲ្យខ្ញុំ ក្នុងគោល បំណងយកមកដាក់វត្ថុសិល្បៈទៅប្រទេសអូស្ត្រាលី។នៅព្រឹក ១៦ ខែកញ្ញា ឈ្មោះ NTO បានយកកាបូបមកអោយគាត់ ហើយម្ចាស់ផ្ទះក៏ឃើញឈ្មោះ NTO នេះយកកាបូបមកឱ្យខ្ញុំដែលគោលបំណងយកវត្ថុអនុស្សាវរីយ៍ផ្ញើទៅឱ្យឈ្មោះ [redacted] ។ គាត់ផ្ញើកាបូបទៅតាមរយៈ [redacted] ជាមិត្តស្រីរបស់គាត់ ដើម្បីផ្ញើទៅអូស្ត្រាលី។ នៅពេលដែល អ៊ិនតុ យកកាបូបមក ខ្ញុំបានឆែកនៅ

នឹងមុខគាត់ដែរតែពុំមានឃើញអ្វីនោះទេ ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ នៅថ្ងៃកើតហេតុមិនមែនប៉ូលីសមកសួរខ្ញុំទេ គឺខ្ញុំជាអ្នកទៅសួរប៉ូលីស ហើយនៅពេលឆែកឆេរ គឺមិនបានបង្ហាញកាបូបនោះនៅចំពោះមុខខ្ញុំទេ ខ្ញុំចេះភាសាខ្មែរ តែខ្ញុំមិនចេះអានទេ ពេលនោះពុំមានអ្នកបកប្រែទេ ។ ខ្ញុំស្គាល់ NWOKO ៦ខែមុន ហើយនៅពេលគេចាប់ខ្ញុំ ខ្លួនគឺបានឃើញក្នុងនោះមានក្រណាត់នៅពេលដែលគេយកកាបូបមក ពេលនោះខ្ញុំឆែកមើលពុំមានឃើញមានថ្នាំញៀនទេ។ នៅពេលគេចាប់ខ្លួន គឺមានប៉ូលីសមកសួរខ្ញុំថាមានស្គាល់ [redacted] ដែរឬទេ ហើយក៏បានឆ្លើយថាស្គាល់ ពេលនោះក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនតែម្តង ពេលដែលខ្ញុំរង់ចាំនៅមុខប្រលានយន្តហោះ ពេលនោះក៏ត្រូវសមត្ថកិច្ចចាប់ខ្លួនដែរ។ នៅពេលដែលសមត្ថកិច្ចឆែកឆេរ គេយកកាំបិទវះកាបូបនៅផ្នែកខាងក្រោយក៏ឃើញមានថ្នាំញៀន។ខ្ញុំជាអ្នកទៅយក Nwoko Preious នៅព្រលានយន្តហោះនៅប្រហែលម៉ោង៦ៈ៣០។ ពេលគេចាប់ខ្លួន គឺចាប់ YOSEHEAMមុន។ ពេលដែលយកកាបូបទៅអោយ ពណ៌ខ្មៅ និងខៀវហើយមិនមែនជាកាតាបនោះទេ។កាតាបនោះឈ្មោះ ស៊ីនគួ បានប្រាប់ថា កាតាបនោះត្រូវដាក់តាមខ្លួន ព្រោះខ្លាចមានការខូចខាតសម្ភារៈនៅខាងក្នុងនោះ ។ ខ្ញុំស្គាល់ឈ្មោះ Choulene មុនថ្ងៃមកប្រទេសកម្ពុជា មិត្តប្រុសរបស់គាត់បានឱ្យខ្ញុំនាំដើរលេង ព្រោះខ្ញុំចេះ ភាសាខ្មែរ ។

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ អ្វីដែលសមត្ថកិច្ចមានប្រសាសន៍គឺត្រឹមត្រូវ ហើយតែពាក្យដែលគាត់និយាយថា ខ្ញុំមានការទាក់ទងគ្នាតាមប្រព័ន្ធ Facebook មិនត្រឹមត្រូវទេ ហើយបើតាមប្រព័ន្ធ Internet គឺបានទាក់ទងជាមួយ Nwoko Preious កាលដែលខ្ញុំបាននិយាយទាក់ទងគ្នា គឺនិយាយពីរឿងធ្វើការងារទេ ព្រោះខ្ញុំមិនបានធ្វើការទាក់ទង Frisis ជាមួយ [redacted] នោះទេខ្ញុំស្គាល់ Nwoko ៨-៩ខែហើយ ហើយកាបូប បានមកពីឈ្មោះ [redacted] នៅពេលធ្វើដំណើរខ្ញុំមានកាតាបពណ៌ខៀវ ហើយពេលនោះខ្ញុំពិនិត្យឃើញកាតាបនោះមានថ្នាំញៀន នៅពេលប៉ូលីសឆែក ហើយកាតាបនោះគេផ្ញើទៅអូស្ត្រាលី ។ កាបូបទាំងពីរនោះ charlene បានបញ្ជាក់ថា កាបូបនោះគឺត្រូវស្ពាយជាប់នឹងខ្លួន នៅពេលដែលប៉ូលីសទៅ ខ្ញុំបានចូលទៅយកកាបូប ពេលនោះមិនដឹងជាគាត់គឺនៅចំពោះមុខខ្ញុំឬយ៉ាងណានោះទេ ខ្ញុំមិនដឹងទេ ព្រោះខ្ញុំភ័យពេក ។ តាមពិតកាបូបនោះខ្ញុំបានទទួលពីឈ្មោះ charlene ផ្ញើទៅឱ្យមនុស្សម្នាក់នៅប្រទេសអូស្ត្រាលី តែខ្ញុំមិនស្គាល់គេទេ ខ្ញុំស្គាល់តែលេខទូរស័ព្ទព្រោះ charlene ប្រាប់ថាពេលទៅដល់នឹងមានគេមកទទួលហើយ។នៅពេលដែលប៉ូលីសឆែកឆេរ ខ្ញុំឃើញមានតែក្រណាត់ប៉ាក់ ពុំមានឃើញអ្វីទេ ។ តែនៅពេលប៉ូលីសឆែកឆេរនៅនឹងមុខ គឺឃើញ ម្សៅ សទៅវិញ។ខ្ញុំទៅមកប្រទេសកម្ពុជាបានចំនួន ៦ដងហើយ ពេលដែលធ្វើដំណើរនោះ Nwoko មិនធ្លាប់បានផ្ញើអ្វីនោះទេ។នៅពេលដែលខ្ញុំមកជាលើកទី២ មកដើម្បីធ្វើកិច្ចសន្យាជាមួយ Nwoko ។

ខ្ញុំទើបតែស្គាល់ [redacted] Charlene តាមរយៈដើរលេង ហើយបានប្រាប់សង្សារគាត់ថាគាត់រកស៊ីនាំរបស់របរមកលក់នៅស្រុកខ្មែរ ប្តីខ្ញុំប្រាប់ទៅ charlene ថា ឪពុករបស់គាត់មានការ៉ាសសាំង នៅពេលដែលខ្ញុំមកស្រុកខ្មែរ គោលបំណងមកបញ្ចប់សញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រ ។

-សាក្សី: លោក [redacted]" ជាសមត្ថកិច្ច" បានឆ្លើយបញ្ជាក់ថា:នៅពេលឃាត់ខ្លួនជនជាប់ចោទ មានព្រះរាជអាជ្ញាលោក [redacted] ចូលរួម គឺឃាត់ខ្លួននៅក្នុងព្រលានយន្តហោះ ហើយនីតិវិធីក្នុងការឃាត់ខ្លួន គឺត្រូវឆែកឆេរ ហើយឃើញជាក់ស្តែងនៅចំពោះមុខជនជាប់ចោទ ក្រោយពេលចាប់បានហើយ នាំយកមកដល់ប៉ុស្តិ៍ទើប រកអ្នកបកប្រែ ។ នៅពេលចុះបង្ក្រាប ខ្ញុំមានតួនាទីជាសមាជិក ក្នុងកិច្ចប្រតិបត្តិការណ៍ ហើយពេលនោះប្រធានរបស់ខ្ញុំ [redacted] និង ស៊ីលា ។

-តាំងពីដំបូងគាត់មានសន្ទនាតាមសង្គម Facebook នៅថ្ងៃទី ១៥-៩-២០១៣ ក្រុមខ្ញុំបានធ្វើការស៊ើបរហូត។ ការទំនាក់ទំនងរបស់គាត់គឺតាមម៉ូរបស់គាត់ (តាមសញ្ញាសម្គាល់របស់គាត់) នៅពេលដែលគាត់ចុះពីព្រលានយន្តហោះ ខ្ញុំមិនបានតាមដានគាត់ទេ តែខ្ញុំបានតាមដាន់គាត់ពេលដែលគាត់ចេញពីសណ្ឋាគាររហូតដល់ព្រលានយន្តហោះ គាត់ស្ពាយកាតាបពណ៌ខ្មៅ ។ នៅពេលឆែកឆេរខ្ញុំមិនបានចូលរួមទេ ។ មុនពេលឆែកឆេរខ្ញុំមិនបានចូលរួមទេ តែផ្នែកព្រលានយន្តហោះ គេធ្វើតេស្តបឋមនៅទីនោះ ហើយនៅពេលនាំខ្លួនមកដល់ការិយាល័យមានលោក [redacted] ជាអ្នកចូលរួមធ្វើការឆែកឆេរ ពេលនោះបានធ្វើការវះកាបូប គឺនៅផ្នែកខាងក្រោយនៃកាបូបនោះ។ នៅថ្ងៃនោះអ្នកដែលហៅ សាលែន ឡើងលើគឺមានសម្លៀកបំពាក់ស៊ីវិល ។ នៅពេលដែលគាត់ចេញមកក្រៅ គឺកាតាបរបស់គាត់នៅខាងក្នុង ក្រោយមកកម្លាំងសមត្ថកិច្ចក៏បានស្លៀកពាក់ជាឯកសណ្ឋាន ហើយមកអញ្ជើញគាត់ទៅក្នុង ដើម្បីធ្វើការឆែកឆេរនៅចំពោះមុខរបស់គាត់ ហើយនៅពេលនោះសមត្ថកិច្ចក៏បានសម្រេចចិត្តឆែកឆេរតែម្តង។ពេលនោះ (យូសេ) គាត់ឡើងទៅចាំនៅខាងលើ ហើយ សាលែន នៅចាំខាងក្រោម ។ នៅពេលចាប់ខ្លួនខ្ញុំបានតាមដានទៅលើ (សាលែន) ព្រោះមានការទាក់ទងតាមប្រព័ន្ធ Facebook ។ ការតាមដានរបស់ខ្ញុំគឺ មិនអាចនិយាយថា ចាប់ពីកន្លែងណាទៅណានោះទេ ព្រោះនេះជាបទបញ្ជារបស់អគ្គបញ្ជាការក្រសួងមហាផ្ទៃ ។ នៅពេលចាប់ខ្លួន Nwoko ខ្ញុំមានការសហការ ពេលនោះឃាត់បានពីនាក់គឺ Taylor និង Savarino មុនទើបឈានទៅចាប់ខ្លួន Nwoko ហើយអ្នកដែលយកកាបូបមកឲ្យអ្នកទាំងបីនោះគឺឈ្មោះ (អិចកូ) ។

-សាក្សីបំភ្លឺ: លោក [redacted] បានបញ្ជាក់ថា ក្រោយពីចាប់ខ្លួនជនជាប់ចោទ និងវត្ថុតាងរួចហើយមក គឺលោក ហ៊ុន រិទ្ធិ ជាអ្នកសួរចម្លើយ ហើយកំណត់រដ្ឋបាលជាអ្នកវែងកសារ ។

## សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

-ជនជាប់ចោទនេះត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅក្នុងព្រលានយន្តហោះ មុនពេលឃាត់ខ្លួនគឺសមត្ថកិច្ចបានធ្វើការតាមដានយ៉ាងល្អិតល្អន់ ដោយសារតែច្បាប់តម្រូវឱ្យផ្តន្ទាទោសទៅលើជនជាប់ចោទណា ដែលបានប្រព្រឹត្តបទល្មើសពិតប្រាកដ ឲ្យបានត្រឹមត្រូវទៅតាមនីតិវិធី

ទើបតំណាងមហាអយ្យការសុំបន្តនៅពេលនេះ ម្យ៉ាងទៀតការប្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ Nwoko ពុំមានភស្តុតាងដោះបន្ទុកឱ្យរួចពីការទទួលខុសត្រូវឡើយ។ ដើម្បីជាមូលដ្ឋានឱ្យតុលាការបានកំណត់ពីទណ្ឌកម្មទៅលើជនជាប់ចោទ ។ ចំណែកជនជាប់ចោទឈ្មោះ S[redacted] charlene និងឈ្មោះ T[redacted]n មហាអយ្យការយល់ថា បុគ្គលទាំងពីរនេះគឺជាជនរងគ្រោះតាមរយៈជនជាប់ចោទឈ្មោះ Nwoko ។ ដោយមានការផ្តល់ពត៌មានពីប្រទេសអូស្ត្រាលីគឺមានការសំដៅទៅលើជនជាប់ចោទឈ្មោះ Nwoko រីឯវត្ថុចាប់យកពីជនជាប់ចោទឈ្មោះ Savari[redacted] និងឈ្មោះ T[redacted] ពិតជាបានពិនិត្យកាបូបបញ្ញើរទាំងអស់គ្នា ប៉ុន្តែការពិនិត្យពេលនោះមិនបានមើលក្នុងកាបូបឱ្យបានល្អិតក្អន់ឡើយ។ដើម្បីសម្រេចផ្តន្ទាទោសលើជនល្មើសជាប់ឱ្យបានត្រឹមត្រូវ ទើបមហាអយ្យការសុំលើកពេលសួរដេញដោលពីថ្ងៃមុន ហើយបានបន្តមកថ្ងៃនេះ គឺយើងបានអញ្ជើញសមត្ថកិច្ចចូលរួមដើម្បីបំភ្លឺឱ្យបានច្បាស់លាស់ ។

-ក្រោយពីបានពិនិត្យត្រឹមត្រូវហើយ តំណាងមហាអយ្យការយល់ថាៈសមត្ថកិច្ចបានចាប់ឃាត់ខ្លួនជនជាប់ចោទឈ្មោះ T[redacted]ដែលមានភស្តុតាងជាប់ជាមួយថ្នាំញៀន ដែលជាបទល្មើសជាក់ស្តែង ហើយបានបន្តទៅឃាត់ខ្លួនជនជាប់ចោទ ០២នាក់ទៀត ។ នីតិវិធីរបស់សមត្ថកិច្ចឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់អាចបញ្ជាក់បានថាៈភស្តុតាងដែលបានដាក់បន្ទុកលើជនជាប់ចោទមានគ្រប់គ្រាន់ រីឯសេចក្តីសម្រេចនៃសាលក្រមសាលាដំបូងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីក្រុមប្រឹក្សាពិចារណាទៅលើជនជាប់ចោទឈ្មោះ [redacted]charlene និងឈ្មោះ T[redacted]Ann ពីភស្តុតាងឱ្យបានល្អិតល្អន់ដើម្បីឈានទៅការសម្រេចផ្តន្ទាទោសលើជនជាប់ចោទ ។

## សេចក្តីសន្និដ្ឋានមេធាវី

***-មេធាវី:*** លោក [redacted] (មេធាវីការពារឈ្មោះ T[redacted]Ann )បានសន្និដ្ឋានថាៈនៅឆ្នាំ ២០១៣ កូនក្តីខ្ញុំបានមកប្រទេសកម្ពុជាតាមរយៈការអូសទាញរបស់ឈ្មោះ Nv[redacted]ous ដើម្បីដើរលេង និងមកធ្វើកិច្ចសន្យាការងារនិងនាំវត្ថុសិល្បៈបើកហាងលក់នៅប្រទេសអូស្ត្រាលីដោយឱ្យប្រាក់ខែ ១.៥០០$ និងជួលហាងលក់ដូរ។ នៅពេលកូនក្តីខ្ញុំបាទមកដល់ប្រទេសកម្ពុជា [redacted]s បានឱ្យឈ្មោះ S[redacted] ទៅទទួលយកពីប្រលានយន្តហោះ ហើយទៅសម្រាកនៅអូតែល(វត្តភ្នំ)។នៅម៉ោង១២ម៉ថ្ងៃត្រង់ ពេលមិនទាន់ចាប់ខ្លួនកូនក្តីខ្ញុំឈ្មោះ Charlene បានយកកាតាបមកឱ្យនិងបានត្រួតពិនិត្យជាមួយគ្នាគ្មានឃើញអ្វីប្លែកក្រៅពីកន្សែងប៉ាក់និងវត្ថុសិល្បៈរបស់ខ្មែរមួយចំនួននោះទេ លុះដល់ម៉ោង ៤ម៉រសៀល Charlene បាននាំកូនក្តីខ្ញុំឈ្មោះ [redacted] ទៅប្រលានយន្តហោះ និងបានផ្តាំថាកុំឱ្យទុកកាតាបឆ្ងាយពីខ្លួន ។ នៅពេលដែលកូនក្តីខ្ញុំអង្គុយត្រៀមឡើងយន្តហោះសមត្ថកិច្ច Police បានទៅដល់និងសុំឆែកកាតាបមើលកូនក្តីខ្ញុំស្រឡាំងកាំងអត់ដឹងមានរឿងអ្វី ? ហើយហុចកាតាបទៅឱ្យ Police ចំណែកឯភិនភាគ

កាតាបនោះគឺមានលក្ខណៈថ្មីស្រឡាងដូចចេញពីរោងចក្រ ពុំមានដាច់រហែកអ្វីបន្តិចឡើយ ដូចដែលសមត្ថកិច្ច Police បានឆ្លើយបំភ្លឺជូនតាំងដំណាក់កាលនៅសាលាដំបូងរាជធានីភ្នំពេញ និងនៅពេលសវនាការសាលាឧទ្ធរណ៍នេះរួចហើយសមត្ថកិច្ច Police វះកាតាបមើលស្រាប់តែឃើញមានថ្នាំញៀនតែម្តង ។ រឿងនេះកូនក្តីខ្ញុំមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ ព្រោះកូនក្តីខ្ញុំត្រូវបានឈ្មោះ Noko បោកប្រាស់ឱ្យមកធ្វើកិច្ចសន្យាការងារ និងរកស៊ីលក់វត្ថុសិល្បៈជាមួយគ្នា ហើយកាតាបនោះទៀត ក៏មិនមែនជារបស់កូនក្តីខ្ញុំដែរ ។ ម្យ៉ាងទៀត Police សហព័ន្ធអូស្ត្រាលី ក៏បានដឹងថាកូនក្តីខ្ញុំត្រូវគេបោកឱ្យមកនាំថ្នាំញៀនទៅប្រទេសអូស្ត្រាលីតាំងពីនៅប្រទេសអូស្ត្រាលីម្ល៉េះ ប៉ុន្តែ Police សហព័ន្ធអូស្ត្រាលី នៅតែបណ្តោយឱ្យកូនក្តីខ្ញុំ T[redacted]r [redacted]Ann មកប្រទេសកម្ពុជាដើម្បីធ្វើនុយ នាំផ្លូវទៅចាប់មេជួញដូរថ្នាំញៀនធំនៅកម្ពុជារហូតត្រូវ Police កម្ពុជាចាប់ខ្លួននៅពេលនេះ ។ យោងតាមច្បាប់រដ្ឋធម្មនុញ្ញមាត្រា ៣៨ ចំនុចទី ៦ និងមាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាចែងថា វិមតិសង្ស័យត្រូវបានប្រយោជន៍ទៅជនជាប់ចោទ ។

*-សំណូមពរ:* សុំឱ្យតុលាការមេត្តាសម្រេចឱ្យកូនក្តីខ្ញុំ T[redacted] Ann រួចផុតពីបទចោទ ។

*-មេធាវី:* លោក [redacted](ជាមេធាវីការពារឱ្យឈ្មោះ S[redacted])សន្និដ្ឋានថា: កូនក្តីខ្ញុំមិនមានការទំនាក់ទំនងជាមួយ Nwoko ក្នុងរឿងរកស៊ីនោះទេ គឺគាត់មានទំនាក់ទំនងក្នុងផ្លូវស្នេហា ហើយការដែលមានពាក់ព័ន្ធក្នុងរឿងនេះគឺ Nwoko បានពឹងពាក់គាត់ឲ្យយកឲ្យ ហើយការយកនេះគឺពុំមានបានទទួលផលប្រយោជន៍អ្វីនោះទេ តាមពិតកូនក្តីខ្ញុំមិនបានដឹងថា ក្នុងកាបូបដែលផ្ញើនោះមានដាក់គ្រឿងញៀននោះទេ បើប្រសិនជាគាត់ដឹងថាកាបូបនោះមានដាក់គ្រឿងញៀនមែននោះ គឺគាត់មិននៅរង់ចាំរហូតដល់ពេលប៉ូលីសចាប់ខ្លួននោះទេ ព្រោះពេលនោះកូនក្តីខ្ញុំគាត់បានទៅសួរដល់សមត្ថកិច្ចទៀតផង។តាមពិតទៅកូនក្តីខ្ញុំ ជាអ្នករកស៊ីបើកហាងមិនធ្លាប់មានទោសទណ្ឌនោះទេ បើយើងពិនិត្យទៅលើភាពជាក់ស្តែង នូវសកម្មរបស់ Nwoko បញ្ជាក់ឱ្យឃើញថាក្នុងរឿងនេះកូនក្តីខ្ញុំជាជនរងគ្រោះពិតប្រាកដ ។

*សំណូមពរ:* សុំឱ្យតុលាការមេត្តាសម្រេចឱ្យកូនក្តីខ្ញុំរួចផុតបទចោទ ។

*-មេធាវី:*លោក[redacted] ជាមេធាវីការពារឱ្យ N[redacted]Chineme បានធ្វើសេចក្តីសន្និដ្ឋានថា: កាបូបនោះនៅពេលដែលគាត់ទទួលពីឈ្មោះ NTO គឺឃើញក្រណាត់ប៉ាក់ពុំមានអ្វីទេ ។ កាបូបដែលគេផ្ញើមកនោះ គឺគោលបំណងក្នុងន័យជាអ្នករកស៊ីជាមួយគ្នា ។ ការទំនាក់ទំនងរវាងឈ្មោះ [redacted] Ann និង [redacted] Chineme គឺទំនាក់ទំនងតាមប្រព័ន្ធ FaceBook ស្គាល់គ្នាបានរយៈពេល ៦ខែហើយ Taylor កាត់បានមកប្រទេសកម្ពុជា ៣ដង ហើយគឺមកដើម្បីលក់វត្ថុអនុស្សាវរីយ៍ រីឯឈ្មោះ ចាស្ទីន ជាមិត្តភក្តិនៅក្រុមហ៊ុន ។ ចំពោះឈ្មោះ វីស៊ីម៉ា ខ្ញុំមិនធ្លាប់បានប្រគល់ប្រាក់ឱ្យគាត់ទេ ។ ហើយខ្ញុំទំនាក់ទំនងឈ្មោះ [redacted]harlene ចំណែកឯឈ្មោះ [redacted]

[redacted] Ann មិនធ្លាប់បានស្គាល់គ្នាទេ ។ ចំពោះការទំនាក់ទំនងគ្នា ខ្ញុំធ្លាប់ស្គាល់ [redacted] Ann ច្រើនជាង [redacted] Charlene ។ កូនក្តីខ្លួនជាអ្នករកស៊ីពីប្រទេសកម្ពុជា ទៅប្រទេសអូស្ត្រាលី គឺជួញដូរតែវត្ថុអនុស្សាវរីយ៍ ហើយកូនក្តីខ្លួនបានទទួលបញ្ញើរជាកាបូប ម្ចាស់កាបូបនោះបានប្រាប់មកឲ្យកូនក្តីខ្លួនថាកាបូបនេះមានតែក្រណាត់ប៉ាក់ ពុំមានអ្វីផ្សេងទេ ។ តែក្នុងករណីនេះតាមចម្លើយរបស់ Toylor គឺមានការប្តូរចម្លើយ គឺគ្រាន់តែមានការខុសគ្នាបន្តិចដែលបណ្តាលមកពីអ្នកបកប្រែគ្មានជំនាញ ហើយផ្អែកតាមកំណត់ហេតុនៅនគរបាលយុត្តិធម៌ក៏បានបញ្ជាក់ដែរថា នៅពេលសាកសួរគឺពុំមានអ្នកបកប្រែត្រឹមត្រូវនោះទេ ការចាប់ខ្លួនកូនក្តី របស់ខ្ញុំគឺធ្វើឡើងមិនត្រឹមត្រូវតាមនីតិវិធីនោះទេ ។ តាមពិតកូនក្តីខ្ញុំគ្រាន់តែបង្ហោះតាម Twechat មិនមែន Facebook នោះទេ ហើយភស្តុតាងទាំងនេះ គឺមិនត្រឹមត្រូវតាមផ្លូវច្បាប់នោះឡើយ ។ម្យ៉ាងវិញទៀតក្នុងការឃាត់ខ្លួនកូនក្តីខ្ញុំ សមត្ថកិច្ចក៏បានបញ្ជាក់ដែរថា ក្នុងនោះមានជនជាប់ចោទឈ្មោះ NTO ដែរ ហើយជននោះក៏ត្រូវបានរត់គេចខ្លួនបាត់ ហើយការចោទប្រកាន់មកលើកូនក្តីខ្ញុំនេះគឺមិនត្រឹមត្រូវនោះទេ ។

*សំណូមពរៈ* សុំបន្ធូបន្ថយទោស ។

-ក្រោយពីបានស្តាប់អំណានរបាយការណ៍សង្ខេបអង្គហេតុ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានតំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានមេធាវីជនជាប់ចោទ

-ក្រោយពីបានឯកសារភស្តុតាងក្នុងសំណុំរឿង

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

## **សាលាឧទ្ធរណ៍**
## **យល់ឃើញថា**

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខៈ ៣៣៤ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] Chineme,បណ្តឹងឧទ្ធរណ៍លេខៈ ៣៦១ ចុះថ្ងៃទី២០-៦-២០១៤ របស់ឈ្មោះ [redacted] Ann និងបណ្តឹងឧទ្ធរណ៍លេខៈ ៣៦៣ ចុះថ្ងៃទី២៣-៦-២០១៤ របស់មេធាវីទទួលសិទ្ធិលើជនជាប់ចោទឈ្មោះ [redacted] Charlene ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ៥០ កប២ "ធ" ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ២០១៤ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]hineme,ឈ្មោះ [redacted]Charlene

និងឈ្មោះ [redacted] Ann បានឆ្លើយបដិសេធថាមិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ដោយឈ្មោះ [redacted] Chineme បានឆ្លើយបញ្ជាក់ថា កាបូបដែលឈ្មោះ [redacted] Ann និងឈ្មោះ [redacted] Charlene ទទួលពីខ្លួន គឺបានមកពីឈ្មោះ NTO ដើម្បីយកទៅឱ្យ Cathryn នៅអូស្ត្រាលី ។ ពេលឈ្មោះ Cathryn ប្រគល់កាបូបឱ្យឈ្មោះ [redacted] Chineme ឈ្មោះនេះបានបើកមើលពុំឃើញមានគ្រឿងញៀនទេ។ឯឈ្មោះ [redacted]harlene ក៏បានឆ្លើយបញ្ជាក់ថាខ្លួនគ្រាន់តែទទួលបញ្ញើរពីឈ្មោះ [redacted] Chineme ដើម្បីយកកាបូបឱ្យឈ្មោះ [redacted]n ជនជាតិអូស្ត្រាលី ហើយឆែកកាបូបមើល ពុំឃើញមានអ្វីក្រៅពីក្រណាត់ដែលមានរូបចំលាក់ ហើយឱ្យឈ្មោះ [redacted] Ann ស្ពាយជាប់និងខ្លួន តាមបណ្តាំ Nwoko Preious Chineme ។ ខ្លួននិងឈ្មោះ [redacted] Chineme ជាសង្សារនឹងគ្នា។ ខ្លួនមិនដឹងថាក្នុងកាបូបមានគ្រឿងញៀនទេ ។ ចំពោះចម្លើយរបស់ឈ្មោះ [redacted]Ann បានបញ្ជាក់ថាខ្លួនមិនដឹងថាក្នុងកាបូបមានគ្រឿងញៀនទេ គ្រាន់តែទទួលបញ្ញើរឈ្មោះ [redacted]Chineme ឱ្យយកកាបូបទៅឱ្យគេនៅអូស្ត្រាលីតាមលេខទូរស័ព្ទ។ពេលឆែកកាបូបគឺឆែកទាំងអស់គ្នា ហើយបានថតទុកទៀតក្រែងមានបាត់សម្ភារៈ ហើយពុំឃើញមានគ្រឿងញៀនទេ មានតែគ្រឿងចំលាក់ តែពេលសមត្ថកិច្ចវះកាត់កាបូប បែរជាឃើញមានម្សៅស ។ កាបូបនេះឈ្មោះ Charlen ប្រាប់ថាឱ្យយកតាមខ្លួន ព្រោះកន្លងមក នាងថាធ្លាប់បាត់ម្តងហើយ ទើបសម្រេចយកកាបូបដាក់តាមខ្លួន ។

៣-តាមការសន្និដ្ឋានរបស់សមត្ថកិច្ចបញ្ជាក់ថា ដោយសារតែ មានការទទួលពត៌មានពីប្រទេសអូស្ត្រាលីដែលបានឃាត់ខ្លួនឈ្មោះ Cathryn និងឈ្មោះ David ទាក់ទងនិងគ្រឿងញៀនដែលដាក់ក្នុងកំព្យូទ័រយួរដៃ ដែលបានទទួលពីឈ្មោះ [redacted] Charlene ។ ក្រោយការស៊ើបអង្កេតដ៏ស្វិតស្វាញរបស់សមត្ថកិច្ច ទើបឈានដល់ការចាប់ឃាត់ខ្លួនជនជាប់ចោទទាំងបីមានឈ្មោះ [redacted]Chineme, [redacted] Ann និងឈ្មោះ [redacted]harlene.ដកហូតបានថ្នាំញៀនជាក់ស្តែងដែលលាក់ក្នុងកាបូបធ្វេងគាត់ព្រលានយន្តហោះទៅប្រទេសអូស្ត្រាលីនិងបន្តឃាត់ខ្លួនឈ្មោះ [redacted] Charlene ជនជាតិបារាំង ដែលជាអ្នកផ្តល់កាបូបឱ្យរួមជាមួយឈ្មោះ [redacted]Chineme ជនជាតិនីហ្សេរីយ៉ា ផងដែរ ដែលជាអ្នកចាត់ចែងក្នុងអំពើនេះ ។

៤-តំណាងមហាអយ្យការបានសន្និដ្ឋានថា: សមត្ថកិច្ចបានចាប់ឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] Ann ជាប់ជាមួយថ្នាំញៀន ដែលជាបទល្មើសជាក់ស្តែង ហើយបន្តឃាត់ខ្លួនជនជាប់ចោទ ០២នាក់ទៀត ។ នីតិវិធីរបស់សមត្ថកិច្ចត្រឹមត្រូវតាមច្បាប់ ដូច្នេះឃើញថាមានកស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ សូមតម្កល់សាលក្រម របស់សាលាដំបូងទុកជាបានការ ។

៥-មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]Ann បានសន្និដ្ឋានថា: កូនក្តីខ្លួនមកទំនាក់ទំនងជាមួយឈ្មោះ [redacted]Chineme ដោយសារមានការសន្យាបើកហាងលក់

ដូរនៅកម្ពុជា ហើយមានការយកកាបូបតាមខ្លួន ដោយសារមានបញ្ញើរបស់ឈ្មោះ [redacted] Chineme ពេលឆែកកាបូបពុំឃើញមានគ្រឿងញៀនទេ ហើយឈ្មោះ CHarlen ប្រាប់ថាឱ្យស្ពាយតាមខ្លួន ដូច្នេះការចោទប្រកាន់លើជនជាប់ចោទគ្រាន់តែជាវិមតិសង្ស័យតែប៉ុណ្ណោះ ដោយសារជនជាប់ចោទមិនបានដឹងថាមានគ្រឿងញៀន យោងតាមមាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ មាត្រា ៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ វិមតិសង្ស័យត្រូវសម្រេចឱ្យរួចផុតបទចោទប្រកាន់ ។

៦-តាមសេចក្តីសន្និដ្ឋានរបស់មេធាវីការពារឱ្យឈ្មោះ [redacted]Chineme ថាជនជាប់ចោទជាកូនក្តីខ្លួនមិនបានប្រព្រឹត្តទេ គឺឈ្មោះ NTO ជាអ្នកមកទំនាក់ទំនង ហើយពឹងឱ្យផ្ញើរកាបូបនេះទៅប្រទេសអូស្ត្រាលី មានក្រណាត់បាក់ និងរូបចំឡាក់ ហើយបានឆែកកាបូប មើលជាមួយឈ្មោះ Charlen ពុំឃើញមានថ្នាំញៀនទេ គឺឈ្មោះ NTO ជាម្ចាស់កាបូប កាបូបយកមកបង្ហាញមិនមែនកាបូបនាពេលសវនាការសាលាដំបូងទេ។សំណូមពរឱ្យរួចផុតបទចោទប្រកាន់។

៧-មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted]Charlene បានសន្និដ្ឋានថាៈ ជនជាប់ចោទជាកូនក្តីខ្លួនគ្រាន់តែជាសង្សាររបស់ឈ្មោះ [redacted] Chineme តែប៉ុណ្ណោះ ហើយទទួលបណ្តាំសង្សារឱ្យយកកាបូបឱ្យឈ្មោះ [redacted]Ann ។ ឆែកកាបូបមើលពុំឃើញមានថ្នាំញៀនទេ។ ពេលបាត់ឈ្មោះ [redacted]Ann យូរទើបទៅសួរប៉ូលីសរកនាង ទើបសមត្ថកិច្ចនាំខ្លួនតែម្តង បើមានពាក់ព័ន្ធនិងរឿងគ្រឿងញៀននេះ ជនជាប់ចោទឈ្មោះ Charlen មិនមកសាកសួរប៉ូលីសទេ ប្រាកដជាគេចខ្លួនហើយ ដូច្នេះពុំមានភស្តុតាងដាក់បន្ទុកទេ សុំរួចផុតបទចោទប្រកាន់ ។

៨-ក្រុមប្រឹក្សាយល់ថាតាមសេចក្តីសន្និដ្ឋាន របស់មេធាវីការពារឱ្យជនជាប់ចោទសុទ្ធតែសន្និដ្ឋានថាៈ ជនជាប់ចោទមិនជាប់ពាក់ព័ន្ធ និងបទល្មើសគ្រឿងញៀននេះទេ ប៉ុន្តែវត្ថុតាងជាថ្នាំញៀនបានដកហូតពីជនជាប់ចោទដាក់ស្តែងនៅព្រលានយន្តហោះហើយថ្នាំញៀននេះមានទំនាក់ទំនងជាមួយជនជាប់ចោទ ០២នាក់ ទៀត គឺឈ្មោះ [redacted] Chineme និងនាង Charlen ហើយការផ្តល់ពត៌មានរបស់ប្រទេសអូស្ត្រាលី ដែលឃាត់ខ្លួនជនល្មើសគ្រឿងញៀននៅប្រទេសអូស្ត្រាលីបញ្ជាក់ថា ថ្នាំញៀនទាំងនោះ ជនជាប់ចោទពីប្រទេសកម្ពុជាអ្នកបញ្ជូនទៅឱ្យ ។ ដូច្នេះឆ្លងតាមការស្រាវជ្រាវ និងការដកហូតវត្ថុតាងជាក់ស្តែង ចម្លើយឆ្លើយទំនាក់ទំនងគ្នារវាងជនជាប់ចោទទាំងបីសរឱ្យឃើញថា ពិតជាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ ដូចសាលាដំបូងបានសម្រេចតាមសាលក្រមពិតមែន ។

-ក្រុមប្រឹក្សាយល់ឃើញថាពិតជាមានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ដូចបានចោទប្រកាន់ ។

៩-ក្រុមប្រឹក្សាយល់ឃើញថា សាលាដំបូងរាជធានីភ្នំពេញ បានលើកយកសំអាងហេតុបញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ

ដោយពុំចាំបាច់សរសេរសំអាងហេតុដដែលនោះបញ្ជាក់សារជាថ្មីទៀតទេ ។

សេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខៈ ៥០ កប២ "៥" ចុះថ្ងៃទី ២៨-៥-២០១៤ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ គប្បីតម្កល់ទុកជាបានការដដែល ។

**ហេតុដូច្នេះ**

**និងិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍លេខៈ ៣៣៤ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] Chineme, បណ្តឹងឧទ្ធរណ៍លេខៈ ៣៦១ ចុះថ្ងៃទី ២០-៦-២០១៤ របស់ឈ្មោះ [redacted] Ann និងបណ្តឹងឧទ្ធរណ៍លេខៈ ៣៦៣ ចុះថ្ងៃទី ២៣-៦-២០១៤ របស់ជនជាប់ចោទឈ្មោះ [redacted] Charlene ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ ៥០ កប២ "៥" ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល ។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមនីតិវិធី។

-សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០១៦ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] Chineme, ឈ្មោះ [redacted] Ann, និងជនជាប់ចោទឈ្មោះ [redacted] Charlene និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៦ ចំពោះមុខជាប់ចោទឈ្មោះ [redacted] Chineme, ឈ្មោះ [redacted] Ann , [redacted] Charlene ។

-បើកសិទ្ធិប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| លោក [redacted] | លោក [redacted] លោកស្រី [redacted] | លោក [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី 05 ខែ 12 ឆ្នាំ២០១៦

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**